# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខៈ ១០៧ MISTI / ២០២១

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញសេចក្តីសម្រេចលេខ ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលសរសេរកាត់ថា « **ក.វ.ផ.ល.**»។

**ប្រការ២.-**

សេចក្តីសម្រេចនេះ មានវិសាលភាពគ្របដណ្តប់លើការកសាង ការធ្វើបច្ចុប្បន្នភាព និងតម្រូវការនានានៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែលៈ misti.smcabinet@gmail.com

**ប្រការ៣.-**

**គ.ខ.ផ.ល.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុច បូរ៉ា** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **សឹម ណារ៉ា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **សឹន សុថា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | អនុប្រធាន |
| ៤- លោក **ចាតសូ សុភ័ក្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិកអចិន្ត្រៃយ៍ |
| ៥- លោក **ឡៅ សត្យា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | សមាជិក |
| ៦- លោកស្រី **គ្រី ណាល់លីស** | អគ្គនាយករងនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៧- លោក **បោង អង្គារ៉ា** | អគ្គនាយករងនៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ៨- លោក **ចេង លឹមជី** | ប្រធាននាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៩- លោក **ហួន សុវង្សី** | ប្រធាននាយកដ្ឋានកិច្ចការសិប្បកម្មនៃអគ្គនាយកដ្ឋាន សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម | សមាជិក |
| ១០- លោក **សោម គន្ធា** | ប្រធាននាយកដ្ឋានគោលនយោបាយទឹកស្អាត នៃអគ្គនាយកដ្ឋានទឹកស្អាត | សមាជិក |
| ១១- លោក **កែ ប៊ុនធឿន** | ប្រធាននាយកដ្ឋានផ្ទេរបច្ចេកវិទ្យានៃអគ្គនាយកដ្ឋាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១២- លោក **យ៉ែម ណារិទ្ធិ** | ប្រធាននាយកដ្ឋានព័ត៌មាននៃវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ១៣- លោក **អ៊ឹង ប៉ោស្រ៊ី** | ប្រធាននាយកដ្ឋានជំរុញអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ១៤- លោក **ហេង ប៊ុនហួរ** | អនុប្រធាននាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ១៥- លោក **ឈាន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម | សមាជិក |
| ១៦- លោក **ម៉ៅ ព្រហស្បតិ៍** | អនុប្រធាននាយកដ្ឋានវាយតម្លៃ និងទទួលស្គាល់ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម | សមាជិក |
| ១៧- លោក **ជា ថារក្ស** | អនុប្រធាននាយកដ្ឋានបញ្ញត្តកម្មនៃវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ១៨- លោក **សូ ផល្លា** | អនុប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ១៩- កញ្ញា **ឌិន ចរណៃ** | មន្ត្រីនៃអគ្គនាយកដ្ឋានទឹកស្អាត | សមាជិក |
| ២០- លោក **កែវ ដារ៉ា** | មន្ត្រីនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៨៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៤.-**

**គ.វ.ផ.ល.** មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំផែនការសម្រាប់អនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- បង្កើត ឬធ្វើបច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្ត ដោយ៖
    - កំណត់បញ្ហាដែលត្រូវសិក្សា វិភាគ និងវាយតម្លៃលើផលប៉ះពាល់ ស្របតាមតម្រូវការចាំបាច់នៃសង្គម
    - កំណត់ពីគោលបំណងដែលចង់បាន
    - កំណត់នូវជម្រើស ដើម្បីធ្វើការដោះស្រាយ និងសម្រេចនូវគោលបំណង ដែលត្រូវដោះស្រាយតាមចរិកលក្ខណៈនៃផលប៉ះពាល់ធៀបនឹងបច្ចុប្បន្នភាពនៃតម្រូវការក្នុងសង្គម
    - វិភាគលើផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន ដើម្បីកំណត់ជម្រើស
    - សិក្សា អង្កេត ប្រមូលទិន្នន័យ និងប្រឹក្សាយោបល់ជាមួយបុគ្គល និង/ឬអង្គភាពពាក់ព័ន្ធតាមភាពចាំបាច់នៃបញ្ហា ដោយគិតចាប់ពីជំហានដំបូងនៃការកំណត់បញ្ហាដល់ចុងបញ្ចប់នៃដំណោះស្រាយបញ្ហា
    - ធ្វើសេចក្តីសន្និដ្ឋាន និងកំណត់ជម្រើសសមស្របបំផុត ដើម្បីធ្វើការដោះស្រាយ
- បំពេញនូវតម្រូវការសង្គមក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងត្រួតពិនិត្យឡើងវិញនូវតម្រូវការ ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្របតាមកាលៈទេសៈជាក់ស្តែង
- បណ្តុះបណ្តាល អប់រំ ណែនាំឱ្យមានការយល់ដឹងពីផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តដល់មន្ត្រីសមត្ថកិច្ចជំនាញ
- សហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីគាំទ្រ និងអនុវត្តសកម្មភាពវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- ទទួលសំណើវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តពីគ្រប់អង្គភាពជំនាញចំណុះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- បូកសរុបរបាយការណ៍លទ្ធផលការងារជូនថ្នាក់ដឹកនាំក្រសួង។

**ប្រការ៥.-**

**គ.វ.ផ.ល.** មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានសមាសភាព និងភារកិច្ច ដូចតទៅ៖

**ក- សមាសភាព**

| | | |
|---|---|---|
| ១- លោក **ចេង លឹមជី** | ប្រធាននាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | ប្រធាន |
| ២- លោក **ហេង ប៊ុនហួរ** | អនុប្រធាននាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | អនុប្រធានប្រចាំការ |
| ៣- លោកស្រី **សេង ស៊ីណា** | ប្រធានការិយាល័យច្បាប់នៃនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | អនុប្រធាន |
| ៤- លោក **ប៊ួយ មង្គល** | ប្រធានការិយាល័យនីត្យានុកូលនៃនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៥- លោក **ណាត សំណាង** | អនុប្រធានការិយាល័យច្បាប់នៃនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |
| ៦- កញ្ញា **តាន់ ឆេងប៉** | អនុប្រធានការិយាល័យច្បាប់នៃនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | សមាជិក |



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

**ខ- ភារកិច្ច៖**

- ទំនាក់ទំនង សម្របសម្រួលការងារជាមួយក្រសួង ស្ថាប័ន អង្គភាព អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា
- សម្របសម្រួលការងារជូន ក.វ.ផ.ល.
- រៀបចំកម្មវិធីសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំនានាជូន ក.វ.ផ.ល.
- បូកសរុបលទ្ធផលការងារ និងធ្វើរបាយការណ៍ជូន ក.វ.ផ.ល. តាមការកំណត់
- អនុវត្តការកិច្ចផ្សេងទៀតដែល ក.វ.ផ.ល. ប្រគល់ជូន។

**ប្រការ៦.-**

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាននីតិកម្ម គ្រប់អង្គភាពក្រោមឱវាទក្រសួង និងសមាសភាពដូចមានចែងក្នុងប្រការ៣ និងប្រការ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៩ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mistimcabinet@gmail.com